# ព្រះរាជក្រម

នស/រកម/១២០៦/០៣៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជនរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ជំពូកទី ១
# បទប្បញ្ញត្តិស្តីពីវិសោធនកម្ម

## ផ្នែកទី ១
## បទប្បញ្ញត្តិស្តីពីការកែប្រែមាត្រាមួយចំនួន នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

**មាត្រា ១.-**

មាត្រា ៦ មាត្រា ៧ មាត្រា ១៣ មាត្រា ១៤ មាត្រា ១៥ មាត្រា ១៧ មាត្រា ២៦ មាត្រា ៣៥ មាត្រា ៣៩ មាត្រា ៤២ មាត្រា ៥៤ និងមាត្រា ៦០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ព្រមទាំងត្រូវបានកែប្រែដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ត្រូវបានកែប្រែដោយបទប្បញ្ញត្តិដូចតទៅ :

**មាត្រា ៦.-ថ្មី**

----------

----------

----------

Collection by VCAT Professional Consultant

---

---

---

មាត្រា ២.–

---

---

---

## ផ្នែកទី ២

## បទប្បញ្ញត្តិស្តីពីពន្ធដារ

មាត្រា ៣.–

មាត្រា ៣០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ១១ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានកែប្រែដូចខាងក្រោម :

មាត្រា ៣០.–ថ្មី

មូលដ្ឋានកំណត់ពន្ធគឺជាថ្លៃដីគិតតាមថ្លៃទីផ្សារ តាមទីក្រុង និង តាមតំបន់នីមួយៗ ដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡា ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ យ៉ាងយឺតបំផុតនៅថ្ងៃទី ៣០ ខែ មិថុនា នៃឆ្នាំប្រមូលពន្ធ ។

មាត្រា ៤._ថ្មី

មាត្រា ៧ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម :

មាត្រា ៧._ថ្មី

ប្រាក់ចំណោញជាប់ពន្ធ គឺជាប្រាក់ចំណោញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិប-ត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណោញមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្ម ការប្រាក់ ថ្លៃឈ្នួល និង សួយសារ ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ទ្រព្យសកម្មវិនិយោគ រាប់ទាំងអចលនទ្រព្យផង ។ ប្រាក់ចំណោញជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណោញមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬ ទ្រព្យវិនិយោគ ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលសម្រេចបានមកពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម ។ និយមន័យនៃពាក្យ "អចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ទ្រព្យវិនិយោគ ការសម្រេចបាន" ព្រមទាំងការកំណត់មូលដ្ឋានគិតពន្ធ វិធាន និងនីតិវិធីនៃការប្រមូល ប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៥._

រូបវន្តបុគ្គល និង នីតិបុគ្គល ដែលប្រកបសេវាកម្មវាយតម្លៃ និង ជួញដូរអចលនទ្រព្យ ត្រូវមានវិញ្ញាបនប័ត្រវិជ្ជាជីវៈ និង ការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ វិធាន និង នីតិវិធី ក្នុងការចេញវិញ្ញាបនប័ត្រវិជ្ជាជីវៈ និង ការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៣

## បទប្បញ្ញត្តិស្តីពីការកែប្រែមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

មាត្រា ៦._

មាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង

ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ១៧._ថ្មី**

ចំណូលនៃថវិកាខេត្ត-ក្រុងរួមមានចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ ដែលបានផ្ទេរពីថវិការដ្ឋ ឬ បង្កើតឡើងដោយច្បាប់ដោយឡែក ។ ខេត្ត-ក្រុងគ្មានសិទ្ធិសំរេចក្នុងការខ្ចីទេ ។

១-ត្រូវបានផ្ទេរពីថវិការដ្ឋទៅថវិកាខេត្ត-ក្រុង នូវចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដូចតទៅ :

**ក/ចំណូលសារពើពន្ធ :**

-ពន្ធប្រថាប់ត្រា

-ពន្ធលើដីធ្លីមិនបានប្រើប្រាស់

-អាករសំរាប់បំភ្លឺសាធារណៈ (អាករបន្ថែមលើស្រា និង ចារី)

-អាករលើការស្នាក់នៅ

-ពន្ធសត្តឃាដ

-ពន្ធប៉ាតង់

-ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

**ខ/ចំណូលមិនមែនសារពើពន្ធ :**

..................................................................................................................

..................................................................................................................

..................................................................................................................

**មាត្រា ១៦.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៦
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំរាប់បញ្ជាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

ពរល.០៦១២.៥៥៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ : ៤៩៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០០៦
**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**